74

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# ប្រកាស

## ស្តីពី

## ក្របខណ្ឌសមត្ថភាពស្នូល សម្រាប់គិលានុបដ្ឋាកវជ្ជាជីវៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខែ សីហា ឆ្នាំ ២០១២ក្រសួងសុខាភិបាល នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស

Australian AID

World Health Organization

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ......៦៤០.........អបស.អឧឃ

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៨

# ប្រកាស
# ស្តីពី
# ក្របខណ្ឌសមត្ថភាពស្នូល សម្រាប់គិលានុបដ្ឋាកឧបដ្ឋាយិកាជីវៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

***

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ-បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា៦ នៃអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ២០ សសរ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៧ ស្តីពីការតែងតាំងសមាសសភាពគណៈកម្មាធិការប្រឡងថ្នាក់ជាតិ សម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញលិខិតឧទ្ទេសនាមរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ០៥/១១ គ.ប.ជ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការតែងតាំងគណៈកម្មការគ្រប់គ្រង និងសម្របសម្រួលដើម្បីរៀបចំការប្រឡងចេញថ្នាក់ជាតិ
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល ,លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៤២៦ ០៣៤/៨៨៤ ៩០៩ ទូរស័ព្ទៈ (៨៥៥-២៣) ៧២២ ៩៣៣

## សម្រេច

ប្រការ ១.- គិលានុបដ្ឋាកវិជ្ជាជីវៈ ត្រូវមានសមត្ថភាពស្នូលដើម្បីធានាប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការផ្តល់សេវាថែទាំវេជ្ជសាស្ត្រ។

ប្រការ ២.- ក្របខណ្ឌសមត្ថភាពស្នូលរបស់គិលានុបដ្ឋាកវិជ្ជាជីវៈរួមមាន ចំណេះដឹង ជំនាញ អាកប្បកិរិយា ដែលទាក់ទងនឹងមូលដ្ឋានគ្រឹះវិទ្យាសាស្ត្រសម្រាប់ការថែទាំវេជ្ជសាស្ត្រ ការផ្តល់សេវាថែទាំអ្នកជំងឺ ព្រមទាំងឥរិយាបថវិជ្ជាជីវៈ និងឥរិយាបថបុគ្គល។

ប្រការ ៣.- ក្របខណ្ឌសមត្ថភាពស្នូលរបស់គិលានុបដ្ឋាកវិជ្ជាជីវៈ មានចែងលម្អិតនៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយ ដែលអភិវឌ្ឍដោយគណៈកម្មការមួយ មានតំណាងមកពីក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជា គណៈវិជ្ជាជីវៈពាក់ព័ន្ធ ព្រមទាំងគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលសាធារណៈ និងឯកជន។

ប្រការ ៤.- ក្របខណ្ឌសមត្ថភាពស្នូលរបស់គិលានុបដ្ឋាកវិជ្ជាជីវៈ ត្រូវបានដាក់ឲ្យប្រើប្រាស់សម្រាប់ការកែសម្រួលកម្មវិធីសិក្សា ការអភិវឌ្ឍន៍ពិធីសារប្រឡង ឬ ជាឯកសារយោងសម្រាប់ការអភិវឌ្ឍន៍គុណភាពវិជ្ជាជីវៈថែទាំ។

ប្រការ ៥.- ក្របខណ្ឌសមត្ថភាពស្នូលរបស់គិលានុបដ្ឋាកវិជ្ជាជីវៈ អាចធ្វើការកែលម្អបាន អាស្រ័យមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

ប្រការ ៦.- ពិធីសារប្រឡងនៃការប្រឡងចេញថ្នាក់ជាតិ សម្រាប់អ្នកដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក និងថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក ត្រូវឆ្លើយតបជាមួយនឹងក្របខណ្ឌសមត្ថភាពស្នូល ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

ប្រការ ៧.- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨.- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល មានភារកិច្ចអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ម៉ម_ប៊ុនហេង**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការប្រឡងថ្នាក់ជាតិ សម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- ដូចប្រការ៣ និងប្រការ៨
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## ស្តីពី

## ក្របខណ្ឌសមត្ថភាពស្នូល សម្រាប់គិលានុបដ្ឋាកវិជ្ជាជីវៈ

## នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខែ សីហា ឆ្នាំ ២០១២

# មាតិកា


សេចក្តីផ្តើម ...... ៣

គោលបំណងនៃក្របខ័ណ្ឌ ...... ៣

បែបបទនៃការអភិវឌ្ឍន៍ក្របខ័ណ្ឌសមត្ថភាពស្នូល ...... ៤

រចនាសម្ព័ន្ធរបស់ក្របខ័ណ្ឌសមត្ថភាពស្នូល ...... ៥

I. មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រសម្រាប់ការថែទាំវេជ្ជសាស្ត្រ ...... ៥

ក. វិទ្យាសាស្ត្រជីវវេជ្ជសាស្ត្រ ...... ៥

ខ. វិទ្យាសាស្ត្រឥរិយាបថ ...... ៦

គ. វិទ្យាសាស្ត្រថែទាំវេជ្ជសាស្ត្រ ...... ៦

II. ការផ្តល់សេវាថែទាំអ្នកជំងឺ ...... ៩

ក. ការថែទាំអ្នកជំងឺ ...... ១០

ខ. ដំណើរការថែទាំវេជ្ជសាស្ត្រ ...... ១១

គ. ទម្រង់ការថែទាំវេជ្ជសាស្ត្រគ្លីនិក ...... ១៤

III. ឥរិយាបថវិជ្ជាជីវៈនិងបុគ្គល ...... ១៦

ក.អាកប្បកិរិយា ទំនួលខុសត្រូវផ្នែកក្រមសីលធម៌ និងច្បាប់ ...... ១៦

ខ.ការប្រាស្រ័យទាក់ទង ...... ១៧

គ.ការបម្រើសេវាដល់សាធារណជន ...... ១៧

ឃ.ការអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត ...... ១៨

ឧបសម្ព័នទី១៖ បញ្ជីសមាជិកក្រុមការងារ ...... ១៩

ឧបសម្ព័នទី២៖ បញ្ជីសមាជិកគណៈកម្មាការដឹកនាំ ...... ២០

ឧបសម្ព័នទី៣៖ តួនាទីនិងភារកិច្ចគិលានុប្បដ្ឋាក ...... ២១

ឧបសម្ព័នទី៤៖ មាតិការសមត្ថភាពជំនាញមូលដ្ឋានគ្រឹះវិទ្យាសាស្ត្រ ...... ២២

ក. វិទ្យាសាស្ត្រជីវវេជ្ជសាស្ត្រ ...... ២២

ខ. វិទ្យាសាស្ត្រឥរិយាបថ ...... ២៤

គ. វិទ្យាសាស្ត្រនៃការថែទាំវេជ្ជសាស្ត្រ ...... ២៤

ឧបសម្ព័នទី៥៖ មាតិការសមត្ថភាពជំនាញទម្រង់ការ ថែទាំវេជ្ជសាស្ត្រគ្លីនិក ...... ២៨

ឧបសម្ព័នទី៦៖ បញ្ជីឯកសារយោង ...... ៣២

# ក្របខណ្ឌសមត្ថភាពស្នូល សម្រាប់គិលានុបដ្ឋាកវិជ្ជាជីវៈ
# នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## សេចក្តីផ្តើម

នៅក្នុងព្រះរាជាណាចក្រកម្ពុជា គិលានុបដ្ឋាកភាគច្រើនធ្វើការនៅក្នុងប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងមន្ទីរពេទ្យជាតិ ឬមន្ទីរពេទ្យ និងគ្លីនីកឯកជន ឬអង្គការក្រៅរដ្ឋាភិបាល និងគ្រឹះស្ថានបណ្តុះបណ្តាល។

គិលានុបដ្ឋាកដែលអនុវត្តការងារនៅក្នុងទីកន្លែងណាក៏ដោយ ត្រូវតែគោរពតាមវិធាន និងបទដ្ឋានគតិយុត្តិរបស់ប្រទេស ព្រមទាំងបទដ្ឋានវិជ្ជាជីវៈដូចដែលបានកំណត់ដោយក្រសួងសុខាភិបាល និងគណៈគិលានុបដ្ឋាកកម្ពុជា។ ពួកគេត្រូវមាន និងអនុវត្តនូវចំណេះដឹងថែទាំវេជ្ជសាស្ត្រជាមូលដ្ឋាន ដើម្បីបំពេញតួនាទីរបស់ពួកគេបានត្រឹមត្រូវ និងដើម្បីបណ្តុះបណ្តាលនិស្សិតគិលានុបដ្ឋាក និងអ្នកដទៃទៀត។ ពួកគេតម្រូវឲ្យអនុវត្តសកម្មភាពស្រាវជ្រាវ និងការអភិវឌ្ឍវិជ្ជាជីវៈជាបន្ត សំដៅថែរក្សា និងធ្វើបច្ចុប្បន្នភាពសមត្ថភាពស្នូល និងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន។

## គោលបំណង

ក្របខណ្ឌសមត្ថភាពស្នូលនៅក្នុងឯកសារនេះសំដៅទៅលើ ចំណេះដឹង ជំនាញ អាកប្បកិរិយា និងឥរិយាបថដែលបុគ្គលម្នាក់ៗអភិវឌ្ឍឡើងតាមរយៈការបណ្តុះបណ្តាល និងបទពិសោធន៍ការងារ។ ក្របខ័ណ្ឌសមត្ថភាពស្នូលសម្រាប់គិលានុបដ្ឋាកវិជ្ជាជីវៈ (បរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្ររងគិលានុបដ្ឋាក) គឺជាបណ្តុំនៃសមត្ថភាពជំនាញជាសារវន្តដែលគិលានុបដ្ឋាកត្រូវតែមាន ដើម្បីអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួននៅគ្រប់ទីកន្លែងធ្វើការទាំងអស់។

ក្របខណ្ឌនេះត្រូវបានបង្កើតឡើងជាមូលដ្ឋាន សម្រាប់ការអភិវឌ្ឍន៍ពិធីសារប្រឡងនៃការប្រឡងចេញថ្នាក់ជាតិរបស់និស្សិត ដែលបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្ររងគិលានុបដ្ឋាក ពីគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជន ដែលក្នុងពេលអនាគតការប្រឡងចេញថ្នាក់ជាតិ និងត្រូវបានយកមកប្រើប្រាស់ជាមូលដ្ឋានក្នុងការផ្តល់អាជ្ញាប័ណ្ណសម្រាប់ការប្រកបវិជ្ជាជីវៈថែទាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គេអាចប្រើក្របខណ្ឌនេះ ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ផ្នែកថែទាំវេជ្ជសាស្ត្រ និងឬ កំណត់ពីចំណុចខ្វះខាតនៅក្នុងកម្មវិធីសិក្សាបច្ចុប្បន្ន ដែលកំពុងត្រូវបានអនុវត្តនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលនានា ព្រមទាំងជាមូលដ្ឋានមួយក្នុងការអភិវឌ្ឍន៍ការបណ្តុះបណ្តាលកម្រិតខ្ពស់ ឬឯកទេសនៅក្នុងផ្នែកថែទាំវេជ្ជសាស្ត្រ។

# បែបបទនៃការអភិវឌ្ឍន៍ក្របខណ្ឌសមត្ថភាពស្នូល

ក្របខណ្ឌសមត្ថភាពស្នូលសម្រាប់គិលានុបដ្ឋាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានអភិវឌ្ឍឡើងតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនលើកច្រើនសារ របស់ក្រុមការងារបច្ចេកទេសមួយ នៅពេលរៀបចំការប្រឡងចេញថ្នាក់ជាតិ ដែលបានចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ២០១១។ ក្រុមការងារបច្ចេកទេសនោះ ត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការប្រឡងថ្នាក់ជាតិ ដែលរួមមានសាស្ត្រាចារ្យ និងគ្រូគិលានុបដ្ឋាកមកពីគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយប្រធានមួយរូបមកពីក្រសួងសុខាភិបាល (សូមមើលឧបសម្ព័ន្ធទី១៖ បញ្ជីសមាជិកក្រុមការងារបច្ចេកទេស)។

ក្របខណ្ឌនេះត្រូវបានអនុម័តដោយគណៈកម្មការសម្របសម្រួលមួយ ដឹកនាំដោយរដ្ឋលេខាធិការនៃក្រសួងសុខាភិបាលមួយរូប ដែលបង្កើតឡើងដោយគណៈកម្មាធិការប្រលងថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល (សូមមើល**ឧបសម្ព័ន្ធទី២៖** បញ្ជីសមាសសភាពគណៈកម្មការសម្របសម្រួល) ដែលមានភារៈកិច្ចសម្របសម្រួល និងជួយផ្តល់ប្រឹក្សាដល់ក្រុមការងារបច្ចេកទេសខាងលើ។

ការបង្កើតក្របខណ្ឌនេះគឺផ្អែកលើមូលដ្ឋានខាងក្រោម៖

- ការពិនិត្យឡើងវិញលើក្របខណ្ឌសមត្ថភាពស្នូលរបស់គិលានុបដ្ឋាកវិជ្ជាជីវៈ នៅក្នុងប្រទេសនានា ដូចជា អូស្ត្រាលី កាណាដា ហ្វីលីពីន និងតំបន់អាស៊ីប៉ាស៊ីហ្វិក
- តួនាទី និងភារកិច្ចរបស់គិលានុបដ្ឋាកកំណត់ដោយក្រសួងសុខាភិបាល (ឧបសម្ព័ន្ធទី៣)
- ចំណេះដឹង និងបទពិសោធជាក់ស្តែងរបស់សមាជិកក្រុមការងារ
- កម្មវិធីសិក្សាថ្នាក់ជាតិសម្រាប់ថ្នាក់ បរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្ររងគិលានុបដ្ឋាក។

ឯកសារដំបូងមួយត្រូវបានធ្វើពង្រាងឡើងនាត្រីមាសទីបីឆ្នាំ២០១១ និងត្រូវបានពិនិត្យឡើងវិញជាបន្តបន្ទាប់ និងកែសម្រួលដោយក្រុមការងារបច្ចេកទេស បន្ទាប់ពីពិគ្រោះយោបល់ជាមួយតំណាងគណៈគិលានុបដ្ឋាកកម្ពុជា និងដៃគូអភិវឌ្ឍន៍។ ក្របខណ្ឌសមត្ថភាពស្នូលសម្រាប់គិលានុបដ្ឋាកវិជ្ជាជីវៈ ត្រូវបានកែលម្អព្រមពេលជាមួយនឹងក្របខណ្ឌសមត្ថភាពស្នូលរបស់វេជ្ជបណ្ឌិត ឱសថការី និងទន្តបណ្ឌិតដែលត្រូវបានបង្កើតឡើងសម្រាប់គោលបំណងដូចគ្នា និងមានទម្រង់តែមួយ។

ឯកសារនេះបង្ហាញពីសមត្ថភាពស្នូលអប្បបរិមា សម្រាប់គិលានុបដ្ឋាកនៅពេលបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររងក្នុងការផ្តល់ការថែទាំវេជ្ជសាស្ត្រប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

# រចនាសម្ព័ន្ធរបស់ក្របខណ្ឌសមត្ថភាពស្នូល

ក្របខណ្ឌសមត្ថភាពស្នូលនេះ កំណត់ពីចំណេះដឹងដែលគិលានុបដ្ឋាកវិជ្ជាជីវៈធ្វើការនៅក្នុងផ្នែកពីគ្រោះជំងឺក្រៅ និងផ្នែកអ្នកជំងឺសំរាកពេទ្យ កំណត់ពីជំនាញដែលពួកគេត្រូវតែមាន និងឥរិយាបថដែលពួកគេត្រូវប្រកាន់យក ក្នុងការអនុវត្តវិជ្ជាជីវៈប្រចាំថ្ងៃរបស់ពួកគេ។

ក្របខណ្ឌក្នុងឯកសារនេះ រួមមានបីជំពូកចម្បងគឺ (១)មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រសម្រាប់ការអនុវត្តការថែទាំវេជ្ជសាស្ត្រ (២)ការផ្តល់ការថែទាំអ្នកជំងឺ និង(៣)ឥរិយាបថវិជ្ជាជីវៈ និងបុគ្គល។

ឯកសារនេះ ត្រូវបានចាត់ទុកថាជាឯកសាររស់រវើកមួយ ហើយរំពឹងថានឹងមានការកែលម្អជាប្រចាំ។ ដូច្នេះតម្រូវឲ្យធ្វើការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពឲ្យបានទៀងទាត់រៀងរាល់ឆ្នាំនៅក្នុងឆ្នាំដំបូង ដើម្បីដោះស្រាយបញ្ហាដែលជួបប្រទះក្នុងពេលអនុវត្តឲ្យបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព ហើយនឹងធ្វើបច្ចុប្បន្នភាពរៀងរាល់បីឆ្នាំម្តង ដើម្បីអោយស្របតាមការវិវត្តន៍នៃវេជ្ជសាស្ត្រថែទាំ និងស្តង់ដាវិជ្ជាជីវៈនៅក្នុងប្រទេស។

គ្រប់ជំពូក និងស្តង់ដាសមត្ថភាពស្នូលទាំងអស់ដែលបានរៀបរាប់ខាងលើ កំណត់ពីលក្ខខណ្ឌតម្រូវ សម្រាប់និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្ររងគិលានុបដ្ឋាក ត្រៀមខ្លួនសម្រាប់ការប្រឡងចេញថ្នាក់ជាតិ ដើម្បីធានាបានគុណភាពនៃការបណ្តុះបណ្តាលទូទាំងប្រទេស។

## I. មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រសម្រាប់ការថែទាំវេជ្ជសាស្ត្រ (Scientific Foundations for Nursing Practices)

គិលានុបដ្ឋាកវិជ្ជាជីវៈ ត្រូវមានចំណេះដឹងអំពីទស្សនទាននៃ (ក)វិទ្យាសាស្ត្រវេជ្ជជីវសាស្ត្រ (ខ)វិទ្យាសាស្ត្រឥរិយាបថ និង (គ)វិទ្យាសាស្ត្រថែទាំវេជ្ជសាស្ត្រ ។

### ក- វិទ្យាសាស្ត្រវេជ្ជជីវសាស្ត្រ (Biomedical Sciences)

គិលានុបដ្ឋាកវិជ្ជាជីវៈ មានសមត្ថភាព៖

១. ពន្យល់អំពីតួនាទីរបស់កោសិកានៅក្នុងសកម្មភាពមេតាបូលីសរបស់រាងកាយ

២. បង្ហាញពីចំណេះដឹងអំពីការរក្សាស្ថេរភាពនៃសរីរាង្គកាយ (homeostasis)

៣. ពិភាក្សាអំពីគោលការណ៍នៃយន្តការរាងកាយល្អ

៤. បង្ហាញពីចំណេះដឹងអំពីដំណើរការសម្របសម្រួលសកម្មភាពរាងកាយ

៥. រៀបរាប់អំពីការឆ្លើយតបប្រភេទអ៊ីមុយណូសាស្ត្ររបស់រាងកាយ និងតួនាទីរបស់អ៊ីមុយនីតេនៅក្នុងការការពាររាងកាយ

៦. បង្ហាញពីចំណេះដឹងអំពីថាមភាពរបស់បេះដូង និងរបត់ឈាម

៧. ពិភាក្សាដំណើរការមេតាបូលីស

៨. ពន្យល់អំពីដំណើរការបន្តពូជ

៩. បង្ហាញពីចំណេះដឹងអំពីយន្តការនៃលក្ខណៈតំណពូជ

១០. ពន្យល់អំពីស្ថានភាពនានា ដែលធ្វើឲ្យបុគ្គលមានលក្ខណៈអំណោយផល(predispose) ទៅនឹងការលុកលុយ និងការបង្កើនចំនួនរបស់មេរោគ និងប៉ារ៉ាស៊ីត

១១. ពិភាក្សាអំពីវិធានការក្នុងការបង្ការ និងត្រួតពិនិត្យពពួកមេរោគ និងប៉ារ៉ាស៊ីត

១២. ពិភាក្សាអំពីទស្សនទាននិងគោលការណ៍នៃអាហារូបត្ថម្ភ និងរបបអាហារ (diet)

១៣. បង្ហាញចំណេះដឹងអំពីប្រភេទក្រុម និងអានុភាពរបស់ឱសថដែលយកមកប្រើ និង

១៤. បង្ហាញពីចំណេះដឹងអំពីកត្តាអេកូឡូស៊ី និងទំនាក់ទំនងរបស់វាទៅនឹងសុខភាព

## ខ. វិទ្យាសាស្ត្រឥរិយាបថ (Behavioural Sciences)

គិលានុបដ្ឋាកវិជ្ជាជីវៈ មានសមត្ថភាព៖

១. បង្ហាញនូវចំណេះដឹងអំពីរចនាសម្ព័ន្ធ និងមុខងារនៃគ្រួសាររបស់ជនជាតិកម្ពុជា

២. វិភាគអានុភាពរបស់អង្គការសង្គម និងស្ថាប័ននានាមកលើជីវិតគ្រួសារនៅកម្ពុជា

៣. បង្ហាញនូវចំណេះដឹងអំពីថាមពលរបស់សហគមន៍ និងអានុភាពរបស់វាមកលើ សុខភាពមនុស្ស

៤. ស្គាល់ពីសណ្ឋានធម្មតានៃការលូតលាស់និងការអភិវឌ្ឍនៅគ្រប់ដំណាក់កាលនៃវដ្តជីវិត

៥. បង្ហាញពីការយល់អំពីអន្តរទំនាក់ទំនងនៃតម្រូវការជាមូលដ្ឋានរបស់មនុស្ស

៦. រៀបរាប់អំពីកិច្ចការអភិវឌ្ឍន៍របស់បុគ្គលនៅដំណាក់កាលផ្សេងៗនៃវដ្តជីវិត

៧. ពន្យល់អំពីថាមភាពនៃឥរិយាបថរបស់មនុស្ស

៨. យល់ពីទ្រឹស្តីនៃការអភិវឌ្ឍបុគ្គលិកលក្ខណៈ

៩. ពិភាក្សាអំពីគោលការណ៍និងទ្រឹស្តីនៃការសិក្សា

១០. រៀបរាប់និងបង្ហាញពីវិធីសាស្ត្រនិងបច្ចេកទេសនៃការកែប្រែឥរិយាបថ

១១. រៀបរាប់ពីគោលការណ៍នៃការសម្ភាស និងការផ្តល់ប្រឹក្សា

## គ. វិទ្យាសាស្ត្រថែទាំវេជ្ជសាស្ត្រ (Nursing Sciences)

គិលានុបដ្ឋាកវិជ្ជាជីវៈ មានសមត្ថភាព៖

១. បង្ហាញនូវចំណេះដឹងអំពីទស្សនទាននៃសុខភាព

២. កំណត់ពីកត្តានានាដែលប៉ះពាល់ដល់សុខភាពរបស់បុគ្គល គ្រួសារ និងសហគមន៍

៣. វាយតម្លៃស្ថានភាពសុខភាពរបស់បុគ្គល ក្រុម និងសហគមន៍ដោយប្រើវិធីសាស្ត្រអេពីដេមីសាស្ត្រ
៤. រៀបរាប់ពីការអង្កេតតាមដានជំងឺ រួមបញ្ចូលទាំងប្រភពនៃព័ត៌មានសម្រាប់តាមដាន និងការប្រើប្រាស់របស់វានៅក្នុងការរៀបចំផែនការ និងការវាយតម្លៃកម្មវិធីសុខភាព
៥. ប្រើធនធានសហគមន៍សមស្របនៅក្នុងការផ្តល់ការថែទាំសុខភាពនៅកម្រិតបឋម កម្រិតទីពីរ និងកម្រិតទីបី
៦. អនុវត្តចំណេះដឹងអំពីការលូតលាស់ និងការអភិវឌ្ឍនៅក្នុងការផ្តល់ការថែទាំសុខភាព
៧. រៀបរាប់អំពីការប៉ាន់ប្រមាណអតិថិជនដែលមានការបង្អាក់តម្រូវការផ្នែកសរីរសាស្ត្រនិងចិត្តសង្គម
៨. ពិភាក្សាអំពីកត្តានានាដែលផ្លាស់ប្តូរសមត្ថភាពរបស់អតិថិជន ដើម្បីបំពេញតម្រូវការផ្នែកសរីរៈសាស្ត្រ និងចិត្តសង្គម (ឧទា. របៀបរស់នៅ បរិស្ថាន សរីរសាស្ត្រ ជីវសាស្ត្រ)
៩. ពិភាក្សាអំពីអានុភាពនៃការផ្លាស់ប្តូរនៅក្នុងការបំពេញតម្រូវការ ចំពោះស្ថានភាពសុខភាពរបស់អតិថិជន (ឧ. វត្តុរាវ អតុល្យភាពអេឡិចត្រូលីត ស្តុក កង្វះអាហារូបត្ថម្ភ លំនាំនៃឥរិយាបថដែលមានបញ្ហា)
១០. ពិភាក្សាអំពីប្រភេទទូទៅនៃលំនាំឥរិយាបថដែលមានបញ្ហាក្នុងចំណោមប្រជាជនកម្ពុជា
១១. ពិភាក្សាអំពីវិធានការដែលនឹងជួយអតិថិជនដោះស្រាយការផ្លាស់ប្តូរនានាដែលបំពេញតម្រូវការផ្នែកសរីរសាស្ត្រ និងចិត្តសង្គម
១២. ពន្យល់អំពីគំរូនៃការព្យាបាលទាំងឡាយដែលត្រូវបានប្រើ ដើម្បីកែតម្រូវបញ្ហាជ្រៀតជ្រែកក្នុងតម្រូវការ (needs interferences)
១៣. បកស្រាយតម្លៃនៃតេស្តរោគវិនិច្ឆ័យ ចំពោះបញ្ហាសុខភាពជាក់លាក់នានា
១៤. សហការជាមួយសមាជិកក្រុមដទៃទៀត ព្រមទាំងវិស័យនិងស្ថាប័ននានានៅក្នុងការផ្តល់ការថែទាំដល់បុគ្គល គ្រួសារ និងសហគមន៍
១៥. សម្របសម្រួលជាមួយសមាជិកក្រុម វិស័យ និងស្ថាប័នដទៃទៀត ក្នុងការបញ្ជូនអ្នកជម្ងឺ ឬ អតិថិជន (referral of clients) អោយបានសមស្រប
១៦. ពន្យល់អំពីថាមពលនៅក្នុងសហគមន៍មួយ ដែលជួយសម្រួល ឬរាំងដល់ការចូលរួមរបស់សហគមន៍
១៧. លើកឡើងនូវអាទិភាព និងផែនការសម្រាប់អន្តរាគមន៍ជាមួយបុគ្គល គ្រួសារ និងសហគមន៍ ដោយផ្អែកលើការវិភាគ ការរំពឹងទុករបស់សហគមន៍ទៅតាមស្តង់ដារប្រតិបត្តិ និងធនធានដែលមាន

១៨. កំណត់ពីការថែទាំជាអាទិភាពសម្រាប់បុគ្គលដែលប្រឈមមុខខ្ពស់ និងក្រុមដែលងាយរងគ្រោះ
១៩. តាក់តែងកម្មវិធីសុខភាពសម្រាប់ក្រុមគោលដៅពិសេស (ឧ. កម្មករ មនុស្សចាស់ និងជនពិការ)
២០. រៀបចំផែនការកម្មវិធីអប់រំសុខភាព ដែលនឹងជួយដល់បុគ្គល គ្រួសារ និងសហគមន៍ឲ្យទទួលខុសត្រូវលើសុខភាពរបស់ពួកគេដោយខ្លួនឯង
២១. បង្ហាញនូវចំណេះដឹងអំពីមូលហេតុ និងផលបច្ច័យនៃអសមតា (unstability) រវាងបុគ្គល និងបរិស្ថានដែលនៅជុំវិញខ្លួនគេ
២២. ប្រើប្រាស់ចំណេះដឹងអំពី វិទ្យាសាស្ត្រជីវរូបវ័ន្ត និងឥរិយាបថនៅក្នុងការថែទាំវេជ្ជសាស្ត្រសម្រាប់អតិថិជនដែលមានបញ្ហាសុខភាព
២៣. បង្ហាញនូវចំណេះដឹងអំពីការទទួលខុសត្រូវរបស់គិលានុបដ្ឋាក នៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ
២៤. បង្ហាញពីសមត្ថភាពកំណត់អាទិភាពនៅក្នុងស្ថានភាពមានគ្រោះអាសន្ន
២៥. ជួយបុគ្គល គ្រួសារ និងសហគមន៍អភិវឌ្ឍជំនាញដើម្បីដោះស្រាយ និងទទួលខុសត្រូវលើការថែទាំសុខភាពដោយខ្លួនឯង
២៦. អនុវត្តកម្មវិធីអប់រំសុខភាពសម្រាប់បុគ្គល គ្រួសារ និងសហគមន៍
២៧. តាក់តែងកម្មវិធីអប់រំសុខភាព ដែលផ្តោតទៅលើការលើកកម្ពស់សុខភាព ការបង្ការជំងឺ និង ការស្តារនីតិសម្បទា
២៨. បង្ហាញពីជំនាញចាប់ផ្តើមនៅក្នុងការអភិវឌ្ឍន៍ អនុវត្ត និងវាយតម្លៃផែនការបង្រៀនសម្រាប់បុគ្គល គ្រួសារ និងសហគមន៍
២៩. រៀបរាប់ពីតួនាទី និងមុខងាររបស់អង្គការសុខភាព អង្គការដែលពាក់ព័ន្ធនឹងសុខភាព និងអង្គការសង្គម និងស្ថាប័ននានាក្នុងប្រទេស
៣០. អនុវត្តការថែទាំវេជ្ជសាស្ត្រ ប្រកបដោយជំនាញវិជ្ជាជីវៈ
៣១. ប្រកាន់ខ្ជាប់ទៅនឹងបទដ្ឋានច្បាប់ និងក្រមសីលធម៌នៅក្នុងការអនុវត្តការថែទាំវេជ្ជសាស្ត្រ
៣២. ពន្យល់អំពីភាពពាក់ព័ន្ធនៃច្បាប់សុខភាពទាក់ទងទៅនឹងការថែទាំសុខភាព សម្រាប់បុគ្គល គ្រួសារ និងសហគមន៍
៣៣. បង្ហាញនូវចំណេះដឹងអំពីសញ្ញានៃការមានផ្ទៃពោះ ព្រមទាំងចំណេះដឹងអំពីការប៉ាន់ប្រមាណនិងការថែទាំចំពោះស្ត្រី ចំពោះទារកទើបកើត ហើយនិងចំពោះគ្រួសារក្នុងរយៈកាលនៃមាតុភាព

៣៤. ពន្យល់អំពីការផ្លាស់ប្តូរផ្នែកសរីរសាស្ត្រ និងចិត្តសង្គមនៅក្នុងបុគ្គល និងគ្រួសារ ទាក់ទងទៅនឹងការមានផ្ទៃពោះ

៣៥. ពិភាក្សាអំពីវិធានការនានាដែលនឹងជួយជំរុញចំណងមេត្រីរវាងទារកនិងឪពុកម្តាយ

៣៦. ពិភាក្សាអំពីកិច្ចការអភិវឌ្ឍន៍របស់គ្រួសារទាក់ទងទៅនឹងការពរពោះ និងការចិញ្ចឹមកូន

៣៧. កំណត់ពីបញ្ហាជាក់ស្តែងនិងបញ្ហាដែលអាចមាន ដែលអាចកើតឡើងនៅក្នុងរយៈពេលមុនសម្រាល ក្នុងពេលសម្រាល និងក្រោយពេលសម្រាល និងការគ្រប់គ្រងដែលបញ្ហាទាំងនេះតាមសមស្រប

៣៨. ពិភាក្សាអំពីតួនាទីរបស់គិលានុបដ្ឋាក នៅក្នុងការគ្រប់គ្រងអតិថិជនដែលមានបញ្ហាសុខភាពជាក់លាក់

៣៩. អនុវត្តគោលការណ៍និងបច្ចេកទេសជាមូលដ្ឋាននៃការគ្រប់គ្រងស្ថានភាពថែទាំវេជ្ជសាស្ត្រ

៤០. ប្រើជំនាញប្រាស្រ័យទាក់ទងក្នុងការកត់ត្រានិងរាយការណ៍ព័ត៌មានអំពីអតិថិជន

៤១. អនុវត្តវិធីសាស្ត្រស្រាវជ្រាវជាមូលដ្ឋាននៅក្នុងការដោះស្រាយបញ្ហាសុខភាព

៤២. ពិនិត្យលទ្ធផលនៃការថែទាំសុខភាពសម្រាប់បុគ្គល គ្រួសារ និងសហគមន៍ទាក់ទងទៅនឹងការសម្រេចបាននូវលទ្ធផលដែលរំពឹងទុក

៤៣. បង្ហាញពីសមត្ថភាពអនុវត្តការថែទាំវេជ្ជសាស្ត្រប្រកបដោយសុវត្ថិភាព។

**បញ្ជីមាតិកាសមត្ថភាពជំនាញ** ស្តីពីមូលដ្ឋានគ្រឹះនៃវិទ្យាសាស្ត្រសម្រាប់ការអនុវត្តការថែទាំវេជ្ជសាស្ត្ររបស់គិលានុបដ្ឋាកវិជ្ជាជីវៈ មានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធទី៣។

## II. ការផ្តល់សេវាថែទាំវេជ្ជសាស្ត្រដល់អ្នកជំងឺ (Provision of Nursing Care Services)

សមត្ថភាពជំនាញស្នូលសម្រាប់ការអនុវត្តការថែទាំវេជ្ជសាស្ត្រ ទាក់ទងទៅនឹងតួនាទី និងទំនួលខុសត្រូវដែលបានកំណត់ដោយក្រសួងសុខាភិបាលសម្រាប់គិលានុបដ្ឋាក។

គិលានុបដ្ឋាកវិជ្ជាជីវៈ អនុវត្តដំណើរការថែទាំវេជ្ជសាស្ត្រជាលក្ខណៈប្រព័ន្ធ និងអនុវត្តទម្រង់ការថែទាំវេជ្ជសាស្ត្រគ្លីនីកសមស្រប ដើម្បីផ្តល់ការថែទាំអ្នកជំងឺប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

នៅក្នុងឯកសារនេះ សេចក្តីបរិយាយពីសមត្ថភាពជំនាញរបស់គិលានុបដ្ឋាកវិជ្ជាជីវៈ ក្នុងការផ្តល់សេវាថែទាំវេជ្ជសាស្ត្រ ត្រូវបានចែកជាបីជំពូកដែលពាក់ព័ន្ធគ្នាទៅវិញទៅមកៈ (ក)ការថែទាំអ្នកជំងឺ (ខ)ដំណើរការ/បែបបទថែទាំវេជ្ជសាស្ត្រ និង(គ)ទម្រង់ការថែទាំវេជ្ជសាស្ត្រ។

## ក. ការថែទាំអ្នកជំងឺ (Patient Care)

គិលានុបដ្ឋាកវិជ្ជាជីវៈ ផ្តល់ការថែទាំដល់អ្នកជំងឺនិងអតិថិជនគ្រប់រូប រួមទាំងម្តាយ និង កុមារ មនុស្សពេញវ័យ និងមនុស្សចាស់។

### ១. ម្តាយ និងកុមារ

គិលានុបដ្ឋាកវិជ្ជាជីវៈ ផ្តល់ការថែទាំវេជ្ជសាស្ត្រដល់៖

- ស្ត្រីក្នុងកំឡុងពេលមានផ្ទៃពោះ និងក្រោយពេលសម្រាល
- ស្ត្រីដែលមានផលវិបាកក្នុងពេលមានផ្ទៃពោះ ពេលឈឺពោះ ពេលសម្រាល និងក្រោយ ពេលសម្រាល (ស្ថានភាពដែលអាចមានគ្រោះថ្នាក់/ហានិភ័យខ្ពស់)
- ទារកទើបនឹងកើត (ការដាក់ពិន្ទុអាប់ហ្គា/APGAR ការពិនិត្យរកជំងឺទារក ការថែរក្សា ដំណើរការរាងកាយនានា ដូចជាអុកស៊ីសែន សីតុណ្ហភាព ។ល។)
- ទារកដែលអាចមានគ្រោះថ្នាក់/ហានិភ័យខ្ពស់ (កើតមិនគ្រប់ខែ មិនគ្រប់លក្ខណៈពី កំណើត មានការឆ្លងរោគ)
- ស្ត្រីដែលមានបញ្ហាក្នុងការបន្តពូជ និងរោគស្ត្រី

### ២. មនុស្សពេញវ័យ និងមនុស្សចាស់

គិលានុបដ្ឋាកវិជ្ជាជីវៈ ផ្តល់ការថែទាំវេជ្ជសាស្ត្រដល់មនុស្សពេញវ័យ និងមនុស្សចាស់ រួមមាន ៖

- ការថែទាំអតិថិជនដែលឈឺចុកចាប់
- ការថែទាំក្នុងពេលវះកាត់
- ការប្រែប្រួលនៅក្នុងដំណើរការមុខងាររបស់មនុស្ស (បញ្ហាកង្វះអុកស៊ីសែន បញ្ហា ដំណើរការមេតាបូលីសនិងអង់ដូគ្រីន ការបញ្ចេញលាមកនិងទឹកនោម វត្ថុរាវនិង អេឡិចត្រូលីត រលាកនិងការឆ្លងរោគ បញ្ហាដំណើរការប្រព័ន្ធអ៊ីមុយណូសាស្ត្រ បញ្ហា ដំណើរការកោសិកា អតិថិជនដែលមានវិបត្តិជីវសាស្ត្រ ការថែទាំក្នុងពេលសង្គ្រោះ បន្ទាន់និងក្នុងពេលមានគ្រោះមហន្តរាយ)។
- បញ្ហានៃការយល់ដឹងដោយវិញ្ញាណ/perception និងបញ្ហានៃការសម្របសម្រួល/ coordination (ប្រព័ន្ធប្រសាទសាស្ត្រ វិញ្ញាណ សាច់ដុំនិងឆ្អឹង និងបញ្ហាខូចដំណើរការ សរីរាង្គ)
- បញ្ហាសម្របសំរួលនៃឥរិយាបថ/maladaptive patterns of behaviors (ការឆ្លើយតប ដោយភាពអន្ទះសារ និងបញ្ហាពាក់ព័ន្ធនឹងភាពអន្ទះសារ វិបត្តិដំណោក ការបំពាន និង

អំពើហិង្សា ការឆ្លើយ តបដោយអារម្មណ៍ខ្លាំងក្លា និងវិបត្តិផ្លូវអារម្មណ៍ជំងឺវិកលចរិកនិង វិបត្តិផ្លូវចិត្ត ព្រមទាំងវិបត្តិ អារម្មណ៍ដទៃទៀត វិបត្តិជាមួយសង្គមនិងវិបត្តិបុគ្គលិកលក្ខណៈ វិបត្តិគ្រឿងញៀន វិបត្តិក្នុង ការហូបចុក ហើយនិងវិបត្តិផ្លូវភេទ)។

**ខ. ដំណើរការ/បែបបទ ថែទាំវេជ្ជសាស្ត្រ (Nursing Process)**

ដំណើរការ/បែបបទថែទាំវេជ្ជសាស្ត្រ គឺជាឧបករណ៍ឬវិធីសាស្ត្រសម្រាប់រៀបចំនិងផ្តល់ការថែទាំ ឬអន្តរាគមន៍តាមលំដាប់លំដោយ និងមានលក្ខណៈជាប្រព័ន្ធ។ វាគឺជាដំណើរការ/បែបបទគ្លីនីកមួយប្រកបដោយហេតុផលវិទ្យាសាស្ត្រសំរាប់ការថែទាំអតិថិជន។

គិលានុបដ្ឋាកវិជ្ជាជីវៈ អនុវត្តដំណើរការថែទាំវេជ្ជសាស្ត្រដើម្បីផ្តល់ការថែទាំប្រកបដោយគុណភាពគ្របដណ្តប់លើគ្រប់ផ្នែកជាប់ជាបន្ត និងមានស្មេរភាព ដោយកំណត់ពីតម្រូវការថែទាំសុខភាពរបស់អ្នកជំងឺ បង្កើតផែនការថែទាំវេជ្ជសាស្ត្រដើម្បីបំពេញតម្រូវការទាំងនោះ អនុវត្តអន្តរាគមន៍ថែទាំវេជ្ជសាស្ត្រដើម្បីឆ្លើយតបនឹងតម្រូវការ ព្រមទាំងផ្តល់ការថែទាំដោយឡែកសំរាប់បុគ្គលម្នាក់ៗ។

ដំណើរការ/បែបបទថែទាំវេជ្ជសាស្ត្រមាន**ប្រាំដំណាក់កាល** គឺ៖ (១)ការប៉ាន់ប្រមាណតម្រូវការថែទាំវេជ្ជសាស្ត្រ (២)ការធ្វើពាគវិនិច្ឆ័យលើការថែទាំវេជ្ជសាស្ត្រ (៣)ការធ្វើផែនការថែទាំសុខភាព (៤)ការថែទាំវេជ្ជសាស្ត្រ និង(៥)ការវាយតម្លៃការថែទាំអ្នកជំងឺ។

**១. ការប៉ាន់ប្រមាណតម្រូវការថែទាំវេជ្ជសាស្ត្រ (Assessment)**

ជំហានទីមួយនៅក្នុងដំណើរការថែទាំវេជ្ជសាស្ត្រ គឺជាការប្រមូលទិន្នន័យជាលក្ខណៈប្រព័ន្ធ ដើម្បីកំណត់ពីស្ថានភាពសុខភាពរបស់អ្នកជំងឺ និងដើម្បីកំណត់ពីបញ្ហាសុខភាពជាក់ស្តែង ឬដែលអាចមាន។ នៅក្នុងការប៉ាន់ប្រមាណតម្រូវការថែទាំវេជ្ជសាស្ត្រ ប្រភពចម្បងនៃពត៌មានអំពីអ្នកជំងឺ គឺអ្នកជំងឺ គ្រួសារអ្នកជំងឺ និងកំណត់ត្រាវេជ្ជសាស្ត្រកន្លងមករបស់ពួកគេ។

គិលានុបដ្ឋាកវិជ្ជាជីវៈ៖

១.១. ណែនាំឲ្យអ្នកជំងឺចូលរួមក្នុងការប៉ាន់ប្រមាណជាលក្ខណៈប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយមួយនៃតម្រូវការផ្លូវកាយ ផ្លូវចិត្ត ស្មារតី វប្បធម៌ សតិបញ្ញា អភិវឌ្ឍន៍ បរិស្ថាន និងសង្គម

១.២. ប្រើឧបករណ៍និងបច្ចេកទេសប៉ាន់ប្រមាណសមស្រប ដោយពិគ្រោះយោបល់ជាមួយអ្នកជំងឺ និងសមាជិកក្រុមថែទាំសុខភាពដទៃទៀត និង

១.៣. ប្រមូលព័ត៌មានអំពីស្ថានភាពអ្នកជំងឺ ដោយប្រើជំនាញប៉ាន់ប្រមាណ ដោយការសង្កេត សម្ភាស ការសាកសួរប្រវត្តិ ការបកស្រាយទិន្នន័យមន្ទីរពិសោធន៍ ការវាយតម្លៃស្ថានភាពផ្លូវចិត្ត និងការវាយតម្លៃស្ថានភាពរាងកាយ រួមមាន ការពិនិត្យមើល (inspection) ការស្ទាបមើល (palpation) ការស្តាប់ (auscultation) និង ការគោះមើល (percussion)។

**២. ការធ្វើរោគវិនិច្ឆ័យថែទាំវេជ្ជសាស្ត្រ** (Nursing Diagnosis)

ជំហានទីពីរនៅក្នុងដំណើរការ/បែបបទថែទាំវេជ្ជសាស្ត្រ គឺការកំណត់រកបញ្ហានានាដែលអាចត្រូវបានដោះស្រាយដោយអន្តរាគមថែទាំវេជ្ជសាស្ត្រផ្ទាល់។ វាមានគោលបំណងចម្បងដើម្បីកំណត់ពីអាទិភាពនៃការថែទាំវេជ្ជសាស្ត្រ និងតម្រង់អន្តរាគមថែទាំវេជ្ជសាស្ត្រដោយផ្ទាល់ដើម្បីឆ្លើយតបនឹងតម្រូវការជាអាទិភាពរបស់អតិថិជន។

គិលានុបដ្ឋាកវិជ្ជាជីវៈ

២.១. វិភាគ និងបកស្រាយទិន្នន័យដែលបានទទួលនៅក្នុងការប៉ាន់ប្រមាណបញ្ហាសុខភាពអ្នកជំងឺដើម្បីធ្វើការសន្និដ្ឋាន

២.២. កំណត់ពីបញ្ហាសុខភាពរបស់អ្នកជំងឺ (ឬរោគសញ្ញា និងប្រជុំរោគសញ្ញា) និងមូលហេតុនៃបញ្ហា ដោយផ្អែកលើការសាកសួរល្អិតល្អន់ហើយដែលមានលក្ខណៈជាប្រព័ន្ធ និង

២.៣. សហការជាមួយអ្នកជំងឺនិងក្រុមថែទាំសុខភាព ដើម្បីកំណត់ពីតម្រូវការថែទាំសុខភាពរបស់អ្នកជំងឺជាក់ស្តែងក្នុងពេលបច្ចុប្បន្ន និងដែលអាចកើតមានជាយថាហេតុ។

**៣. ផែនការថែទាំវេជ្ជសាស្ត្រ** (Nursing Care Plan)

ជំហានទីបីនៅក្នុងដំណើរការ/បែបបទថែទាំវេជ្ជសាស្ត្រ គឺការបង្កើតគោលដៅនិងផែនការថែទាំ ក្នុងគោលបំណងដើម្បីជួយអ្នកជំងឺដោះស្រាយបញ្ហាដែលបានរកឃើញ។ ផែនការថែទាំវេជ្ជសាស្ត្ររួមមាន (១)ការកំណត់អាទិភាព (២)ការលើកឡើងនូវលទ្ធផលដែលចង់បាន និង (៣)ការជ្រើសរើសអន្តរាគមថែទាំវេជ្ជសាស្ត្រដើម្បីទទួលបាននូវលទ្ធផលដែលចង់បាននោះ។

គិលានុបដ្ឋាកវិជ្ជាជីវៈ

៣.១. ប្រើការសាកសួរល្អិនល្អន់ដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្ត ប្រកបដោយសុភវិនិច្ឆ័យនិងវិជ្ជាជីវៈ ដើម្បីបង្កើតផែនការថែទាំសុខភាព។

៣.២. ប្រើគោលការណ៍នៃការថែទាំសុខភាពបឋមក្នុងការអភិវឌ្ឍផែនការថែទាំសុខភាព

៣.៣. ឲ្យអ្នកជំងឺ និងគ្រួសាររបស់ពួកគេចូលរួមក្នុងការអភិវឌ្ឍផែនការថែទាំសុខភាព

៣.៤. ពិគ្រោះយោបល់ជាមួយសមាជិកដទៃទៀតនៃក្រុមថែទាំសុខភាព ក្នុងការអភិវឌ្ឍផែនការថែទាំសុខភាព

៣.៥. អភិវឌ្ឍផែនការថែទាំសុខភាពអ្នកជំងឺសមស្របមួយ

**៤. ការអនុវត្តផែនការថែទាំវេជ្ជសាស្ត្រ** (Implementation of Nursing Care Plans)

ជំហានទីបួននៅក្នុងដំណើរការ/បែបបទថែទាំវេជ្ជសាស្ត្រ គឺការអនុវត្តផែនការថែទាំតាមរយៈអន្តរាគមថែទាំវេជ្ជសាស្ត្រ។

គិលានុបដ្ឋាកវិជ្ជាជីវៈ៖

៤.១. ផ្តល់ការថែទាំវេជ្ជសាស្ត្រដូចដែលបានកំណត់ក្នុងផែនការថែទាំសុខភាពអ្នកជំងឺតាមរយៈការអនុវត្តអន្តរាគមន៍ថែទាំវេជ្ជសាស្ត្រ (ទម្រង់ការនៃការថែទាំវេជ្ជសាស្ត្រគ្លីនិក/Clinical Nursing Procedures) ប្រកបដោយប្រសិទ្ធិភាពនិងទាន់ពេលវេលា

៤.២. ស្គាល់ ស្វែងរកជំនួយបន្ទាន់និងបន្ទាប់មក ជួយអ្នកដទៃទៀតនៅក្នុងបម្រែបម្រួលដោយរហ័ស នៃស្ថានភាពណាមួយដែលអាចប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពរបស់អ្នកជំងឺ (ដូចជា រោគស្លោកសាច់ដុំបេះដូង (myocardial infarction) ផលវិបាកនៃការវះកាត់ ព្រឹត្តិការណ៍ប្រព័ន្ធប្រសាទស្រួចស្រាវ ស្ទុក ព្រឹត្តិការណ៍ផ្លូវដង្ហើមស្រួចស្រាវ ។ល។)

៤.៣. ផ្តល់ការថែទាំគាំទ្រដល់អ្នកជំងឺដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃនិងយូរអង្វែង (ឧ. បញ្ហាសុខភាពផ្លូវចិត្ត ការប្រើសារធាតុញៀនឬស្រវឹងដែលមានបញ្ហា បញ្ហាបេះដូងសរសៃឈាម និងជំងឺទឹកនោមផ្អែម)

៤.៤. ប្រើប្រាស់ចំណេះដឹងដោយខ្ជាប់ខ្ជួន នៅពេលផ្តល់ការថែទាំសម្រាប់តម្រូវការផ្នែកសរីរសាស្ត្រ និងចិត្តសាស្ត្រ ដើម្បីជៀសវាងការកើតឡើងនូវផលវិបាកនានា (ដូចជា ការដាក់បញ្ចូលខ្យល់ និងការដកដង្ហើម/ventilation and respiration ឲ្យបានជាអតិបរិមារបត់ឈាម/circulation តុល្យភាពវត្ថុរាវ និងអេឡិចត្រូលីត/fluid and electrolyte balance កាត់បន្ថយការឈឺចុកចាប់ កាត់បន្ថយផលរំខានរបស់ឱសថ ។ល។)

៤.៥. អនុវត្តគោលការណ៍សុវត្ថិភាពការអនុវត្តដោយផ្អែកលើភស្តុតាង និងបទពិសោធន៍កន្លងមក វិធានការត្រួតពិនិត្យការចម្លងរោគ និងឧបករណ៍ការងារសមស្របនៅពេលផ្តល់ការថែទាំវេជ្ជសាស្ត្រដើម្បីបង្ការគ្រោះថ្នាក់/របួសដល់អ្នកជំងឺ ដល់ខ្លួនឯង ដល់ក្រុមថែទាំសុខភាព ដល់បុគ្គលិកដទៃទៀត និងដល់សាធារណជន

៤.៦. អនុវត្តយុទ្ធសាស្ត្រសម្រាប់ការប្រើប្រាស់ឱសថដោយសុវត្ថិភាពនិងសមស្រប

៤.៧. បង្ហាញពីការអនុវត្តដែលមានការទទួលខុសត្រូវផ្នែកបរិស្ថាន (ដូចជា ការបោះចោលកាកសំណល់ ថាមពលសន្សំសំចៃ និងការប្រើប្រាស់ឡើងវិញ)

៤.៨. គ្រប់គ្រងអន្តរាគមន៍ព្យាបាលប្រកបដោយសុវត្ថិភាព (ឧ. ការដាក់អ្នកជំងឺក្នុងស្ថានភាពព្យាបាលណាមួយ/positioning ការព្យាបាលតាមសរសៃវ៉ែន/intravenous therapy ការដាក់បំពង់បង្ហូរ/drainage tube ការថែទាំស្បែកនិងរបួស ហើយនិងការទំនាក់ទំនងចិត្រសាស្ត្រ-សង្គមជាមួយអ្នកជំងឺ/psychosocial interaction)

៤.៩. អនុវត្តការប្រតិបត្តិដោយផ្អែកលើភស្តុតាង/បទពិសោធន៍កន្លងមក សម្រាប់ការបង្ការនិងការ បំបាត់ការឈឺចាប់របស់អ្នកជំងឺ ដោយប្រើប្រាស់ឱសថនិង ការព្យាបាលក្រៅពីឱសថ

៤.១០. រៀបចំអ្នកជំងឺសម្រាប់ទម្រង់ការរោគវិនិច្ឆ័យនិងការព្យាបាល ផ្តល់ការថែទាំក្រោយ

រោគវិនិច្ឆ័យ អនុវត្តទម្រង់ការ បកស្រាយគំហើញ ព្រមទាំងផ្តល់ការថែទាំតាមដានបន្តតាមសមស្រប

៤.១១. ផ្តល់ការថែទាំថែទាំវេជ្ជសាស្ត្រ ដើម្បីបំពេញតម្រូវការថែទាំអ្នកជំងឺដែលជិតស្លាប់/មិនអាចជាសះស្បើយបាន ការថែទាំសម្រន់ ឬដំណាក់កាលចុងក្រោយ (ឧ. ការបំបាត់ការឈឺចាប់និងរោគសញ្ញា ការគាំទ្រផ្នែកស្មារតី និងការផ្តល់យោបល់)

៤.១២. សហការជាមួយសមាជិកក្រុមថែទាំសុខភាពដទៃទៀត ក្នុងការអនុវត្តយុទ្ធសាស្ត្រនានាដើម្បីបង្ការជំងឺ និងរបួស (ឧ. ជំងឺឆ្លង អំពើហិង្សា ការបំពាន ការព្រងើយកន្តើយ ការប្រើសារធាតុដែលមានបញ្ហា (problematic substance use) បញ្ហាសុខភាពផ្លូវចិត្ត គ្រោះមហន្តរាយសហគមន៍ និងគ្រោះអាសន្ន) និង

៤.១៣. ផ្តល់ការអប់រំសុខភាពដល់អ្នកជំងឺ និងគ្រួសារ ដើម្បីលើកកម្ពស់សុខភាព និងបង្ការជំងឺ។

**៥. ការវាយតម្លៃចំពោះការថែទាំអ្នកជំងឺ** (Evaluation of Patient Care)

ជំហានចុងក្រោយនៅក្នុងដំណើរការ/បែបបទថែទាំវេជ្ជសាស្ត្រ គឺការកំណត់ពីការឆ្លើយតបរបស់អ្នកជំងឺទៅនឹងអន្តរាគមន៍ថែទាំវេជ្ជសាស្ត្រ និងវិសាលភាពនៃការសម្រេចបាននូវគោលដៅ។

គិលានុបដ្ឋាកវិជ្ជាជីវៈ៖

៥.១. ប្រើប្រាស់ការសាកសួរល្អិតល្អន់ដើម្បីវាយតម្លៃការថែទាំអ្នកជំងឺដោយទាន់ពេលវេលា

៥.២. តាមដានប្រសិទ្ធភាពនៃការថែទាំអ្នកជំងឺ ដោយសហការ និងពិគ្រោះយោបល់ជាមួយបុគ្គល គ្រួសារ ក្រុម និងសហគមន៍ និងសមាជិកដទៃទៀតនៃក្រុមថែទាំសុខភាព

៥.៣. ផ្លាស់ប្តូរ និង កែតម្រូវការថែទាំអ្នកជំងឺទៅតាមស្ថានភាពបុគ្គលម្នាក់ៗ ដោយផ្អែកលើអាទិភាពនៃបញ្ហាសុខភាពដែលលេចចេញឡើង ដោយសហការជាមួយអ្នកជំងឺ និងសមាជិកដទៃទៀតនៃក្រុមថែទាំសុខភាព

៥.៤. ផ្ទៀងផ្ទាត់ថា អ្នកជំងឺបានទទួល និងយល់ពីព័ត៌មាននិងជំនាញជាសារវ័ន្ត ដើម្បីក្លាយជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងការថែទាំផ្ទាល់ខ្លួនរបស់ពួកគេ

៥.៥. រាយការណ៍ និងកត់ត្រាដោយត្រឹមត្រូវ និងទាន់ពេលវេលានូវព័ត៌មានស្តីពីការថែទាំអ្នកជំងឺ និងការវាយតម្លៃការថែទាំអ្នកជំងឺជាបន្តមកទៀត។

**គ. ទម្រង់ការ ថែទាំវេជ្ជសាស្ត្រគ្លីនីក** (Clinical Nursing Procedures)

គិលានុបដ្ឋាកវិជ្ជាជីវៈ អនុវត្តទម្រង់ការថែទាំវេជ្ជសាស្ត្រគ្លីនីកដោយជំនាញ និងសមស្របដើម្បីផ្តល់ការថែទាំវេជ្ជសាស្ត្រប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពដល់អ្នកជំងឺ។

សមត្ថភាពជំនាញសម្រាប់ទម្រង់ការថែទាំវេជ្ជសាស្ត្រគ្លីនីក រួមមានដូចខាងក្រោម៖

- ការទទួលឲ្យសម្រាកពេទ្យ ការផ្ទេរ និងការបញ្ចេញអ្នកជំងឺ
- ការសង្កេត និងកត់ត្រា រោគសញ្ញា និងប្រជុំរោគសញ្ញារបស់អ្នកជំងឺ
- ការប្រមូលវត្ថុវិភាគ
- ការរៀបចំគ្រែ
- អនាម័យខ្លួនប្រាណ និងការថែទាំស្បែក
- ការប្រើភាពត្រជាក់ និងកម្តៅក្នុងការព្យាបាល
- ការដាក់ទីតាំងអ្នកជំងឺ
- អាហារូបត្ថម្ភ និងមេតាបូលីស
- ការបញ្ចេញចោលកាកសំណល់លាមក និងទឹកនោម
- ការប្រើឱសថ
- ការថែទាំរបួស
- ការថែទាំវេជ្ជសាស្ត្រមុន និងក្រោយវះកាត់ និង
- ការថែទាំអ្នកជិតស្លាប់ និងការថែទាំអ្នកដែលស្លាប់

នៅពេលអនុវត្តទម្រង់ការទាំវេជ្ជសាស្ត្រណាមួយ គិលានុបដ្ឋាកវិជ្ជាជីវៈ ត្រូវអនុវត្តនូវវិធានការទូទៅនានាដូចខាងក្រោម៖

១. ធ្វើការរំងាប់មេរោគសមស្របតាមបែបវេជ្ជសាស្ត្រ និងសល្យសាស្ត្រ រួមទាំងការលាងដៃមុន និងក្រោយទម្រង់ការ ការប្រើប្រាស់បច្ចេកទេសស្មេរីលប្រកបដោយប្រសិទ្ធភាពនៅពេលផ្លាស់ប្តូរសំលៀកបំពាក់ ការប្រើថ្នាំចាក់ និងការអនុវត្តទម្រង់ការវះកាត់ និងទម្រង់ការដទៃទៀត ដូចជាការដាក់សុងទឹកនោមជាដើម

២. ពន្យល់អំពីទម្រង់ការដល់អ្នកជំងឺមុនពេលចាប់ផ្តើមអនុវត្តទម្រង់ការនោះ និងសង្កេតមើលប្រតិកម្មរបស់អ្នកជំងឺក្នុងពេលអនុវត្តទម្រង់ការ

៣. រក្សាភាពខ្មាសអៀនរបស់អ្នកជំងឺ យោងទៅតាមប្រភេទនៃទម្រង់ការ

៤. ប្រមូលផ្តុំឧបករណ៍មុនពេលចាប់ផ្តើមទម្រង់ការ ថែរទាំបរិក្ខារដែលប្រើរួច និងដាក់វាទៅតាមទីកន្លែងដើមវិញ និង

៥. កត់ត្រាទម្រង់ការនៅពេលបញ្ចប់។

បញ្ជីមាតិកាសមត្ថភាពជំនាញសម្រាប់ទម្រង់ការថែទាំវេជ្ជសាស្ត្រគ្លីនីក
របស់គិលានុបដ្ឋាកវិជ្ជាជីវៈ មានចែងក្នុង<u>ឧបសម្ព័ន្ធទី៥</u>។

**III. ឥរិយាបថវិជ្ជាជីវៈ និងបុគ្គល** (Professional and Personal Behaviors)

គិលានុបដ្ឋាកវិជ្ជាជីវៈ បង្ហាញពីឥរិយាបថដែលឆ្លុះបញ្ចាំងពីលក្ខណៈវិនិច្ឆ័យ ដែលអាចទទួលយកបានសម្រាប់វិជ្ជាជីវៈនេះ និងទទួលស្គាល់ការប្រកបវិជ្ជាជីវៈថែទាំវេជ្ជសាស្ត្រថាជាការងារបញ្ញាវន្តមួយ ដែលតម្រូវឲ្យមានការប្តេជ្ញាចិត្តបម្រើសេវា និងអាកប្បកិរិយាវិជ្ជមានមួយចំពោះការសិក្សាថាជាការទទួលខុសត្រូវមួយជីវិតរបស់ពួកគេ។

ក. អាកប្បកិរិយា ព្រមទាំង ទំនួលខុសត្រូវផ្នែកក្រមសីលធម៌និងច្បាប់ (Attitudes, Ethical and Legal Responsibilities)

**១. អាកប្បកិរិយាវិជ្ជាជីវៈ** (Professional Attitudes)

គិលានុបដ្ឋាកវិជ្ជាជីវៈ គោរពស្វយ័តភាព និងសិទ្ធិរបស់អ្នកជំងឺដោយគ្មានការរើសអើងណាមួយ និងយកចិត្តទុកដាក់លើពួកគេប្រកបដោយការថ្នាក់ថ្នម និងព្រហ្មវិហារធម៌ ព្រម ទាំងបង្ហាញពីការគោរពដោយត្រឹមត្រូវចំពោះសហសេវិក គណៈវិជ្ជាជីវៈ និងអាជ្ញាធរសុខាភិបាល។

**២. គោលការណ៍និងបទដ្ឋានក្រមសីលធម៌** (Ethical Principles and Standards)

គិលានុបដ្ឋាកវិជ្ជាជីវៈ គោរពតាមក្រមសីលធម៌វេជ្ជសាស្ត្រជាធរមាន និងគោលការណ៍ក្រមសីលធម៌ចម្បងនៃស្វយ័តភាព សប្បុរសធម៌ មិនប្រព្រឹត្តកំហុស និងយុត្តិធម៌ ព្រមទាំងអនុវត្តគោលការណ៍នៃភាពសម្ងាត់ ការនិយាយពិតមិនកុហក និងបូរណភាពនៅក្នុងការអនុវត្តការងារប្រចាំថ្ងៃ។

គិលានុបដ្ឋាកវិជ្ជាជីវៈ បង្ហាញពីឥរិយាបថថែទាំអ្នកជំងឺសមស្រប គោរព និងរក្សាសិទ្ធិរបស់អ្នកជំងឺ ដោយផ្អែកលើក្រមសីលធម៌ (ឧ. ការថែទាំប្រកបដោយសុវត្ថិភាព ដោយអាណិតអាសូរយ៉ាងជំនាញ និងមានសីលធម៌ ការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើព័ត៌មានសេចក្តីថ្លៃថ្នូរ រក្សាភាពខ្មាសអៀន ហើយនិងគណនេយ្យភាព) និងរក្សានូវភាពសម្ងាត់របស់អ្នកជំងឺនៅក្នុងគ្រប់ទម្រង់នៃការប្រាស្រ័យទាក់ទង។

**៣. ទំនួលខុសត្រូវផ្នែកច្បាប់** (Legal Responsibilities)

គិលានុបដ្ឋាកវិជ្ជាជីវៈគោរពតាមច្បាប់ និងបទបញ្ញត្តិរបស់ប្រទេសកម្ពុជា និងចូលរួមនៅក្នុងសកម្មភាពវិជ្ជាជីវៈជាច្រើន ទាក់ទងទៅនឹងការអនុវត្តរបស់គិលានុបដ្ឋាកវិជ្ជាជីវៈ ដែលបានចុះបញ្ជីប្រកបវិជ្ជាជីវៈ ដូចដែលតម្រូវឡើងដោយក្រសួងសុខាភិបាល និងគណៈវិជ្ជាជីវៈ។

**៤. ការយល់ព្រមរបស់អ្នកជំងឺ** (Patient Consent)

គិលានុបដ្ឋាកវិជ្ជាជីវៈ អនុវត្តគោលការណ៍នៃការយល់ព្រមរបស់អ្នកជំងឺ ដែលត្រូវបានផ្តល់ព័ត៌មានជាមុនសម្រាប់ការថែទាំអ្នកជំងឺ ទម្រង់ការពោគវិនិច្ឆ័យ និងការព្យាបាល (រួមទាំង

ការយល់ព្រមសម្រាប់ការថែទាំ ការបដិសេធការព្យាបាល និងការបញ្ចេញព័ត៌មានសុខភាពទៅក្រៅ) ការពិនិត្យរកជំងឺ និងការស្រាវជ្រាវ (ដោយផ្តល់ការពន្យល់ច្បាស់លាស់អំពីគោលបំណង ផលប្រយោជន៍ ហានិភ័យ និងជម្រើសជំនួសនានា)។

**ខ. ការប្រាស្រ័យទាក់ទង** (Communication)

គិលានុបដ្ឋាកវិជ្ជាជីវៈ ប្រាស្រ័យទាក់ទងដោយប្រសិទ្ធភាពជាមួយៈ

១. អ្នកជំងឺ (និងក្រុមគ្រួសាររបស់អ្នកជំងឺ) ដោយៈ

- ផ្តល់ការពន្យល់ច្បាស់លាស់ និង/ឬសេចក្តីណែនាំ និងទទួលការយល់ព្រមរបស់អ្នកជំងឺដែលត្រូវបានផ្តល់ព័ត៌មានជាមុន
- ដោះស្រាយដោយប្រសិទ្ធភាពនូវបណ្តឹង និងស្ថានភាពលំបាកដទៃទៀត រួមទាំងការផ្សាយដំណឹងអាក្រក់ ការពិភាក្សាអំពីបញ្ហារសើប និងការពិភាក្សាជាមួយអ្នកជំងឺដែលលំបាក/ហិង្សា
- ផ្តល់ការអប់រំអំពីការលើកកម្ពស់សុខភាព និងការបង្ការជំងឺ និង

២. សហសេវិក ដោយផ្តល់ និងចែករំលែកព័ត៌មានតាមសមស្រប។

**គ.ការបម្រើសេវាដល់សាធារណជន** (Service to the Public)

គិលានុបដ្ឋាកវិជ្ជាជីវៈៈ

១. អនុវត្តនៅក្នុងព្រំដែននៃវិជ្ជាជីវៈថែទាំវេជ្ជសាស្ត្រ នៃប្រព័ន្ធថែទាំសុខភាពនៅក្នុងប្រទេសកម្ពុជា និងបំពេញករណីយកិច្ចរបស់គិលានុបដ្ឋាក ដូចដែលបានកំណត់ដោយក្រសួងសុខាភិបាល និងគណៈគិលានុបដ្ឋាកកម្ពុជា រួមទាំងការថែទាំបឋម ការថែទាំកម្រិតទីពីរ និងការថែទាំកម្រិតទីបី

២. យល់ពីតម្លៃនៃការស្រាវជ្រាវនៅក្នុងការអនុវត្តការថែទាំវេជ្ជសាស្ត្រ និងឆ្លៀតឱកាសដើម្បីអនុវត្តគម្រោងស្រាវជ្រាវ ដោយសហការជាមួយសហសេវិក និងអ្នកស្រាវជ្រាវ

៣. ផ្តល់ការបណ្តុះបណ្តាលដល់និស្សិតគិលានុបដ្ឋាក និងការអប់រំសុខភាពដល់អ្នកជំងឺ និងសហគមន៍

៤. គ្រប់គ្រងធនធានមនុស្ស និងធនធានសម្ភារៈ និង

៥. ធ្វើការជាមួយបុគ្គលិកសុខាភិបាលដទៃទៀតក្នុងបរិបទថែទាំអ្នកជំងឺ ដើម្បីអភិវឌ្ឍឲ្យកាន់តែប្រសើរនូវជំនាញធ្វើការជាក្រុម ជំនាញដឹកនាំ និងជំនាញសម្របសម្រួល។

**ឃ. ការអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត** (Continuing Professional Development)

គិលានុបដ្ឋាកវិជ្ជាជីវៈ តម្រូវឲ្យយល់ និងទទួលខុសត្រូវលើការសិក្សាបន្ត (រហូតមួយជីវិត) ក្នុងបំណងលើកកម្ពស់ជំនាញ ឬសមត្ថភាពរបស់ពួកគេ ដែលជាមធ្យោបាយក្នុងការជំរុញអាជីព និងតួនាទីវិជ្ជាជីវៈរបស់ពួកគេក្នុងសហគមន៍។ គេរំពឹងថាតម្រូវការនេះនឹងក្លាយជាកាតព្វកិច្ចសម្រាប់ គិលានុបដ្ឋាកវិជ្ជាជីវៈទាំងអស់នៅក្នុងប្រទេសកម្ពុជានាពេលអនាគត។

កម្មវិធីសិក្សា និងវិធានការសម្រាប់ការបណ្តុះបណ្តាលបន្តនឹងត្រូវបានរៀបចំឡើង និងចាត់តាំងអនុវត្តដោយគណៈគិលានុបដ្ឋាកកម្ពុជា។ គិលានុបដ្ឋាកវិជ្ជាជីវៈដែលបានចុះឈ្មោះម្នាក់ៗនឹងត្រូវបានឲ្យអនុវត្តនូវសំណើនេះ និងត្រូវផ្តល់ដល់គណៈគិលានុបដ្ឋាកកម្ពុជានូវភស្តុតាងដែលបញ្ជាក់ពីក្រេឌីតនៃការបណ្តុះបណ្តាលបន្ត ដើម្បីរក្សាឈ្មោះរបស់ពួកគេនៅក្នុងបញ្ជីគណៈគិលានុបដ្ឋាក។

គិលានុបដ្ឋាកវិជ្ជាជីវៈ៖

- ប្តេជ្ញារៀនសូត្រអស់មួយជីវិត
- កំណត់ពីតម្រូវការក្នុងការរៀនសូត្រនិងអភិវឌ្ឍន៍ចំណេះដឹង
- ចូលរួមអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈបន្ត
- ធ្វើការរៀនសូត្រឲ្យសមស្រប ដើម្បីសម្រេចនូវតម្រូវការនៃការរៀនសូត្រដែលបានកំណត់
- ធ្វើបច្ចុប្បន្នភាពចំណេះដឹង និងជំនាញ។

## ឧបសម្ព័ន្ធទី១៖ បញ្ជីឈ្មោះក្រុមការងារ

| | | |
|---|---|---|
| ១. លោកជំទាវសាស្ត្រាចារ្យ គ្រុយ លាងស៊ីម | អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | ប្រធាន |
| ២. លោកស្រី សំ សុភ័ក្រទ្រ័ | ន.ឧ.ស ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៣. លោក ចៅ ស៊ីង | ន.អ.ធ.ម ក្រសួងសុខាភិបាល | អនុប្រធាន |
| ៤. លោកស្រី ឆេង ចាន់ណារី | លេខាធិការដ្ឋានគ.ប.ជ | លេខាធិការ |
| ៥. លោកសាស្ត្រាចារ្យជំនួយ អៀម សុផល | ស.វ.ស | សមាជិក |
| ៦. លោកសាស្ត្រាចារ្យជំនួយ តាន់ ជី | ស.វ.ស | សមាជិក |
| ៧. លោក លឹម វុទ្ធី | ស.វ.ស | សមាជិក |
| ៨. លោក ហ៊ុន សេរីវឌ្ឍនា | ស.វ.ស | សមាជិក |
| ៩. លោកសាស្ត្រាចារ្យ លឹម ស៊ុនលី | ស.អ | សមាជិក |
| ១០. លោកវេជ្ជ. ង៉ែត ប៊ុនថា | ស.អ | សមាជិក |
| ១១. លោកសាស្ត្រាចារ្យរង ចាន់ សុវណ្ណឌី | ស.អ | សមាជិក |
| ១២. លោក ផេង ចំរើន | ស.អ | សមាជិក |
| ១៣. លោកសាស្ត្រចារ្យរង នឹម មាលា | វ.វ.ស ខ.ភ.ម | សមាជិក |
| ១៤. លោកសាស្ត្រចារ្យរង ហ៊ីង គង់ | វ.វ.ស ខ.ភ.ម | សមាជិក |
| ១៥. លោកសាស្ត្រចារ្យរង ស លឹមយន | វ.វ.ស ខ.ភ.ម | សមាជិក |
| ១៦. លោកសាស្ត្រចារ្យរង សៅ ស៊ា | វ.វ.ស ខ.ភ.ម | សមាជិក |
| ១៧. លោក មូល ចាន់ថា | សាកលវិទ្យាល័យចេនឡា | សមាជិក |
| ១៨. វេជ្ជ. អ៊ី ម៉ាលី | សាកលវិទ្យាល័យចេនឡា | សមាជិក |
| ១៩. លោក ប៊ុន សៀង ឃីម | សាកលវិទ្យាល័យចេនឡា | សមាជិក |
| ២០. លោក សេក សុផុន | សាកលវិទ្យាល័យឡាយហ្វ | សមាជិក |
| ២១. វេជ្ជ. សាត មុតថា | សាកលវិទ្យាល័យឡាយហ្វ | សមាជិក |

# ឧបសម្ព័ន្ធទី២៖ សមាសភាពគណៈកម្មការសម្របសម្រួល

| | | |
|---|---|---|
| ១- ឯកឧត្តមសាស្ត្រាចារ្យ ជា គ្រុយ | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ប្រធាន |
| ២- ឯកឧត្តមសាស្ត្រាចារ្យ យីត ស៊ុនណារ៉ា | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៣- ឯកឧត្តម លី សុមុនី | អនុរដ្ឋលេខាធិការក្រសួងអ.យ.ក | អនុប្រធាន |
| ៤- ឯកឧត្តម ម៉ៅ ប៊ុននិន | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគ.ទ.ក | សមាជិក |
| ៥- លោកស្រីសាស្ត្រា. គាត ភួង | ប្រធានលេខាធិការដ្ឋានគ.ប.ជ | សមាជិកអចិន្ត្រៃយ៍ |
| ៦- លោកស្រី ម៉ក់ ណាង | អនុប្រធានលេខាធិការដ្ឋានគ.ប.ជ | សមាជិក |
| ៧- លោកវេជ្ជបណ្ឌិត ភុំ សំសុង | អនុប្រធានលេខាធិការដ្ឋានគ.ប.ជ | សមាជិក |
| ៨- កញ្ញាវេជ្ជបណ្ឌិត ទូច សុខនាង | លេខាធិការដ្ឋានគ.ប.ជ | សមាជិក |
| ៩- លោកវេជ្ជបណ្ឌិត វ៉េង ឆាយ | លេខាធិការដ្ឋានគ.ប.ជ | សមាជិក |
| ១០- លោកស្រី ឆេង ចាន់ណារី | លេខាធិការដ្ឋានគ.ប.ជ | សមាជិក |
| ១១- លោក អ៊ឹង ឆាយប៉ោ | លេខាធិការដ្ឋានគ.ប.ជ | សមាជិក |
| ១២- លោក កាក់ រចនា | លេខាធិការដ្ឋានគ.ប.ជ | សមាជិក |
| ១៣- លោក មាស វណ្ណថា | លេខាធិការដ្ឋានគ.ប.ជ | សមាជិក |
| ១៤- លោកវេជ្ជបណ្ឌិត ប៊ុន ស្រ៊ីវ | លេខាធិការដ្ឋានគ.ប.ជ | សមាជិក |
| ១៥- លោកស្រី លឹម រត្ននារី | លេខាធិការដ្ឋានគ.ប.ជ | សមាជិក |
| ១៦- លោកសាស្ត្រា. យក់ សូផាន់ណា | សាកលវិទ្យាធិការ នៃស.វ.ស | សមាជិក |
| ១៧- លោកសាស្ត្រា. សាផុន វឌ្ឍនៈ | សាកលវិទ្យាធិការរង នៃស.វ.ស | សមាជិក |
| ១៨- លោកបណ្ឌិត សឿន សម្បត្តិ | សាកលវិទ្យាល័យអន្តរជាតិ | សមាជិក |
| ១៩- លោកបណ្ឌិត ទន់ សុខសម្បត្តិ | សាកលវិទ្យាល័យអន្តរជាតិ | សមាជិក |
| ២០- លោកសាស្ត្រា.ជំ គឹម ឧត្តរី | វ.វ.ស ខ.ភ.ម | សមាជិក |
| ២១- លោកសាស្ត្រា.ជំ លុក សារ៉ាង | វ.វ.ស ខ.ភ.ម | សមាជិក |
| ២២- លោក ស្រ៊ុន ជីវ៉ែន | សាកលវិទ្យាល័យឡាយហ្វ | សមាជិក |
| ២៣- លោក ជ្រិន ម៉ាក់ | សាកលវិទ្យាល័យឡាយហ្វ | សមាជិក |

## ឧបសម្ព័ន្ធទី៣៖ តួនាទីនិងភារកិច្ចរបស់គិលានុបដ្ឋាក

តួនាទី និងភារកិច្ចរបស់គិលានុបដ្ឋាកកំណត់ដោយក្រសួងសុខាភិបាលក្នុងឆ្នាំ១៩៩៧៖

ក. គិលានុបដ្ឋាក-យិកា ដែលផ្តល់សេវាពីគ្រោះជំងឺក្រៅ៖

- រក្សាកំណត់ត្រាអ្នកជំងឺក្រៅ
- ផ្តល់ការថែទាំសារវ័ន្តដល់អ្នកជំងឺ និងរក្សាកំណត់ត្រានៃការព្យាបាលទាំងអស់
- ជួយគ្រូពេទ្យក្នុងការគ្រប់គ្រងអ្នកជំងឺ
- ធ្វើតាមការណែនាំរបស់គ្រូពេទ្យអំពីការថែទាំអ្នកជំងឺ
- ផ្តល់ការអប់រំសុខភាពដល់អ្នកជំងឺ និងក្រុមគ្រួសារ
- រៀបចំអ្នកជំងឺសម្រាប់ចូលសម្រាកពេទ្យ
- រៀបចំឧបករណ៍បរិក្ខារ និងជួយក្នុងការវះកាត់តូចដែលធ្វើឡើងដោយគ្រូពេទ្យ
- ជួយសង្គ្រោះអ្នកជំងឺក្នុងពេលសង្គ្រោះបន្ទាន់ នៅពេលគ្រូពេទ្យអវត្តមាន

ខ. គិលានុបដ្ឋាកដែលផ្តល់សេវាជំងឺសំរាកពេទ្យ៖

- អប់រំអ្នកជំងឺនិងគ្រួសារអំពីការបង្ការនិងការទប់ស្កាត់ជំងឺ
- ដាក់អ្នកជំងឺក្នុងបន្ទប់ រៀបចំកំណត់ត្រាអ្នកជំងឺ និងជួយសម្រួលដល់អ្នកជំងឺនិងគ្រួសារ
- ជម្រាបដល់គ្រូពេទ្យអំពីអ្នកជំងឺដែលបានចូលសម្រាកពេទ្យដែលត្រូវការការសង្គ្រោះបន្ទាន់ និងជួយសង្គ្រោះអ្នកជំងឺរហូតដល់គ្រូពេទ្យមកដល់
- ជួយគ្រូពេទ្យក្នុងការពិនិត្យអ្នកជំងឺ និងជួយពន្យល់អ្នកជំងឺនិងគ្រួសារអំពីការប្រើប្រាស់ឱសថ ឬមធ្យោបាយផ្សេងទៀតនៃការព្យាបាល
- តាមដានអ្នកជំងឺនៅក្នុងបន្ទប់អ្នកជំងឺ
- ពិនិត្យឡើងវិញប្រចាំថ្ងៃលើការវិវត្តន៍របស់អ្នកជំងឺ និងរាយការណ៍ដល់គ្រូពេទ្យដែលយាម
- ជម្រាបដល់គ្រូពេទ្យអំពីការប្រែប្រួលធំដុំក្នុងលក្ខខណ្ឌរបស់អ្នកជំងឺ
- ធានាថាព័ត៌មានទាំងអស់នៅក្នុងកំណត់ត្រារបស់អ្នកជំងឺ ត្រូវបានសរសេរដោយត្រឹមត្រូវ
- ប្រគល់ព័ត៌មានអំពីអ្នកជំងឺទាំងអស់ដល់គិលានុបដ្ឋាកដែលយាមបន្ត
- ចូលរួមនៅក្នុងការត្រួតពិនិត្យមើលឱសថក្នុងបន្ទប់
- រៀបចំ និងពន្យល់ដល់អ្នកជំងឺ មុនអន្តរាគមន៍ ឬទម្រង់ការណាមួយ
- ណែនាំអ្នកជំងឺអំពីរបបអាហារត្រឹមត្រូវ
- ពន្យល់ដល់អ្នកជំងឺនិងគ្រួសារពួកគេអំពីស្ថានភាពរបស់អ្នកជំងឺ
- ផ្តល់ដំបូន្មានដល់អ្នកជំងឺនិងគ្រួសាររបស់ពួកគេអំពីរបបអាហារ និងការថែទាំនៅផ្ទះបន្ទាប់ពីចេញពីមន្ទីរពេទ្យ និង
- រំងាប់មេរោគបរិក្ខារនិងសម្ភារៈពេទ្យសម្រាប់ប្រើបន្តទៀត

## ឧបសម្ព័ន្ធទី៤៖ មាតិកាសមត្ថភាពជំនាញនៃមូលដ្ឋានគ្រឹះវិទ្យាសាស្ត្រ សម្រាប់ការផ្តល់សេវាថែទាំវេជ្ជសាស្ត្រ

### ក. វិទ្យាសាស្ត្រវេជ្ជជីវសាស្ត្រ (Biomedical Sciences)

១. កាយវិភាគវិទ្យានិង សរីរវិទ្យា (Anatomy and Physiology)

រចនាសម្ព័ន្ធ និងមុខងាររបស់ប្រព័ន្ធរាងកាយចំបងនានា (Structure and function of major body systems)៖ ប្រព័ន្ធស្រោមគ្របដណ្តប់រាងកាយ(integumentary system) ប្រព័ន្ធសាច់ដុំគ្រោងឆ្អឹង (muscular skeletal system) ប្រព័ន្ធបេះដូងនិងសរសៃឈាម (cardiovascular system) ប្រព័ន្ធទឹករងៃ(ឡាំហ្វាទិក lymphatic system) ប្រព័ន្ធផ្លូវដង្ហើម(respiratory system) ប្រព័ន្ធរំលាយអាហារ(digestive system) ប្រព័ន្ធសរសៃប្រសាទ(nervous system) ប្រព័ន្ធក្រពេញបញ្ចេញក្នុង (អង់ដូគ្រីន endocrine system) ប្រព័ន្ធនោម(urinary system) ប្រព័ន្ធបន្តពូជនិងទឹកសរីរៈ និងអេឡិចត្រូលីត (reproductive and body fluid and electrolytes system)។

២. ជីវវិទ្យា ជីវគីមីវិទ្យា និងជីវរូបវិទ្យា (Biology, Biochemistry and Biophysics)

- មុខងារកោសិកា
- ទស្សនទាននៃ homeostasis
- ថាមភាពបេះដូង និងរបត់ឈាម
- ភាពសាយភាយនិងអូស្មូស៊ីស (ការប្តូរឧស្ម័ន ចលនាទឹកក្នុងរាងកាយ វត្ថុរាវ និងតុល្យភាពអេឡិចត្រូលីត)
- ការឆ្លើយតបរបស់អ៊ីមុយណូសាស្ត្រ (ប្រព័ន្ធការពាររាងកាយ ភាពរួសខ្លាំងពេក (hypersensitivity) ប្រព័ន្ធការពាររាងកាយដោយស្វ័យប្រវត្តិ (auto-immunity) )
- ដំណើរការបន្តពូជ
- ដំណើរការមេតាបូលីស (ការលេបចូលអាហារទៅក្នុងខ្លួន ការរំលាយអាហារ ការស្រូបចូល ការបញ្ចេញសារធាតុរាវ (secretion) ការបញ្ច្រាបចូលក្នុងកោសិកា (assimilation) ការបញ្ចេញចោល)
- ការទទួលអារម្មណ៍ និង សមាហរណកម្ម (ការសម្របសម្រួលប្រព័ន្ធប្រសាទ អ័រម៉ូន និងវិញ្ញាណ)

៣. រោគវិទ្យា/សរីរវិទ្យានៃរោគ (Pathology/Pathophysiology)

- គោលការណ៍និងយន្តការនៃជំងឺ រួមទាំងការរលាក និងការជួសជុល ការរំខាន និងថាមភាពលោហិត (hemodynamic) កង្វះខាតផ្នែកការអភិវឌ្ឍ និងការដុះដុំសាច់ (neoplasia)
- រោគសរីរសាស្ត្រនៃស្ថានភាពជំងឺ ដែលត្រូវទទួលអន្តរាគមន៍ថែទាំ

៤. មីក្រូជីវវិទ្យា (Microbiology)

- គោលការណ៍ទូទៅនៃទស្សនទានមីក្រុប
- គោលការណ៍នៃជំងឺឆ្លង
- ទំនាក់ទំនងរវាងមនុស្ស និងប៉ារ៉ាសិត
- អតិសុខុមប្រាណដែលអាចបង្ករោគដល់មនុស្ស
- ការឆ្លើយតបដោយការរលាក/inflammatory response ទៅនឹងភ្នាក់ងារចម្លងរោគ
- ទិដ្ឋភាពគ្លីនិកនៃការចម្លងរោគ
- លក្ខខណ្ឌនៃការលូតលាស់របស់ភ្នាក់ងារចម្លងរោគ
- បែបផែននៃការចម្លងរោគ
- វិធានការទប់ស្កាត់ការចម្លងរោគ

៥. អាហារូបត្ថម្ភ (Nutrition)

- ប្រភេទ ប្រភព និងមុខងារនៃអាហារ និងសារជាតិចិញ្ចឹម
- តម្រូវការអាហារូបត្ថម្ភ និងបុគ្គល នៅក្នុងវដ្តនៃជីវិត
- ទស្សនទាននៃការព្យាបាលដោយរបបអាហារ
  ការកែតម្រូវនូវតម្រូវការរបបអាហារធម្មតា ថាមពល និងសារជាតិចិញ្ចឹម។

៦. ហ្វាម៉ាកូវិទ្យា (Pharmacology)

- ប្រភេទនៃឱសថ
- សកម្មភាពឱសថ
- របៀបប្រើប្រាស់ឱសថ
- ការឆ្លើយតបអវិជ្ជមានទៅនឹងឱសថ
- អញ្ញត្តិដែលមានឥទ្ធិពលលើឱសថ
- ការរក្សាទុកឱសថ
- បទដ្ឋាននិងច្បាប់ឱសថ

៧. អេកូឡូស៊ី (Ecology)

- ផលប៉ះពាល់នៃនគរូបនីយកម្ម និងឧស្សាហកម្មនីយកម្ម (សារធាតុបំពុលនិងផលប៉ះពាល់របស់វាមកលើខ្យល់ ទឹក ដី និងលំហ ការត្រួតពិនិត្យតាមដាននិងការទប់ស្កាត់សារធាតុពុល និងការបំពុល)
- ផលប៉ះពាល់នៃគ្រោះធម្មជាតិ និងគ្រោះមហន្តរាយដែលបង្ករដោយមនុស្ស

**ខ. វិទ្យាសាស្ត្រឥរិយាបថ** (Behavour Sciences)

១. សង្គមវិទ្យា (Sociology)

- រចនាសម្ព័ន្ធ និងមុខងារគ្រួសារនៅកម្ពុជា
- កត្តានានាដែលប៉ះពាល់ដល់ឯកតាគ្រួសារ (ជំនឿវប្បធម៌និងការប្រតិបត្តិ អង្គការសង្គម និងស្ថាប័នសង្គម-សេដ្ឋកិច្ច)
- ថាមភាពសហគមន៍

២. ចិត្តវិទ្យា (Psychology)

- ទ្រឹស្តីនៃការលូតលាស់ និងការអភិវឌ្ឍ
- កិច្ចការអភិវឌ្ឍន៍
- ទ្រឹស្តីនៃតម្រូវការ
